ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.)

World Food Programme

# រាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីស្បៀងអាហារពិភពលោកដាក់ឱ្យដំណើរការនូវបណ្តាញធុរកិច្ចថ្មីមួយ ដែលប្រមូលចងក្រងអាជីវកម្មក្នុងគោលបំណងលើកកម្ពស់អាហារូបត្ថម្ភឱ្យបានកាន់តែប្រសើរឡើង

**រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា** – ថ្ងៃនេះគឺជាថ្ងៃបើកសម្ពោធឱ្យដំណើរការបណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា (SBN Cambodia)។ គំនិតផ្តួចផ្តើមថ្មីមួយនេះប្រមូលផ្តុំនូវអាជីវកម្មនៅក្នុងវិស័យស្បៀងអាហារដែលមានទស្សនវិស័យវែងឆ្ងាយសម្រាប់អនាគត  ដើម្បីពន្លឿនវឌ្ឍនភាព អាហារូបត្ថម្ភនៅទូទាំងប្រទេសកម្ពុជា។

បណ្តាញធុរកិច្ចនេះត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) ដោយមានការគាំទ្រពីកម្មវិធីស្បៀងអាហារពិភពលោក (WFP) ដើម្បីជំរុញកិច្ចសហការនិងការគាំទ្រគ្នាទៅវិញទៅមករវាងវិស័យឯកជន សមាគមធុរកិច្ច រដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួមចំណែក ក្នុងការជំរុញឱ្យមានរបបអាហារសុខភាព និងការអនុវត្តទម្លាប់សុខភាពប្រកបដោយនិរន្តរភាព។ អាជីវកម្មចំនួន២០ បានចុះឈ្មោះជាមួយបណ្តាញធុរកិច្ចក្នុងនាមជាសមាជិកស្ថាបនិកនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា។

អ្នកចូលរួមចំនួន ១១៥ នាក់ មកពីវិស័យឯកជន សមាគមធុរកិច្ច សភាពាណិជ្ជកម្ម និងសង្គមស៊ីវិលបានចូលរួមក្នុងពិធីបើកសម្ពោធនេះ។ អ្នកចូលរួមបានពិភាក្សាអំពីការចូលរួមរបស់វិស័យឯកជនក្នុងការកាត់បន្ថយបញ្ហាអាហារូបត្ថម្ភ និង លើកកម្ពស់ប្រព័ន្ធស្បៀងប្រកបដោយចីរ ដោយអនុវត្តន៍នូវសសរស្តម្ភយុទ្ធសាស្ត្រទាំង៥ នៃចក្ខុវិស័យរបស់បណ្តាញធុរកិច្ច (SBN)។ សសរស្តម្ភយុទ្ធសាស្ត្រទាំង៥មានដូចជា ការបង្កើតឡើងនូវបណ្តាញធុរកិច្ចមួយដ៏រឹងមាំ លើកកម្ពស់ការយល់ដឹងនិងតម្រូវការអាហារូបត្ថម្ភ បង្កើនការផ្គត់ផ្គង់អាហារដែលសម្បូរជីវជាតិនិងអាហារដែលមានបញ្ចូលមីក្រូសារជាតិ ពង្រឹងបរិយាកាសអំណោយផលសម្រាប់លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភនៅក្នុងសហគមន៍ និងនៅកន្លែងធ្វើការ។

ចំពោះ ទោះបីជាសេដ្ឋកិច្ចកម្ពុជាមានកំណើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយក៏ដោយ បញ្ហាកង្វះអាហារូបត្ថម្ភនិងកង្វះមីក្រូសារជាតិនៅតែជាបន្ទុកធ្ងន់មួយ។ កុមារអាយុក្រោមប្រាំឆ្នាំចំនួន១០% ស្គមស្គាំង និង៣២%ក្រិសក្រិន នៅឆ្នាំ២០១៤។

ឯកឧត្តម សុខ ស៊ីឡូ អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទបានមានប្រសាសន៍ថា "យើងមានមោទនភាពចំពោះវឌ្ឍនភាពក្នុងអំឡុងទសវត្សកន្លងមកនេះ ក្នុងការកែលម្អស្ថានភាពអាហារូបត្ថម្ភ ជាពិសេសសម្រាប់កុមារ។"

"ទោះយ៉ាងណាក៏ដោយ នៅមានកិច្ចការជាច្រើនទៀតដែលយើងត្រូវធ្វើ ដើម្បីលុបបំបាត់បញ្ហាអាហារូបត្ថម្ភ។ អាជីវកម្មក្នុងស្រុក គឺជាតួអង្គដែលមិនអាចខ្វះបាន ក្នុងការលើកកម្ពស់គុណភាពអាហារសម្រាប់ប្រជាជនកម្ពុជា ហើយយើងសង្ឃឹមថា ការបើកឱ្យដំណើរការនូវបណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជានេះ រួមជាមួយនឹងការគាំទ្រជាបន្តបន្ទាប់របស់យើងទៅលើវិស័យឯកជន នឹងសរបញ្ជាក់ឱ្យឃើញច្បាស់នូវសារៈសំខាន់ និងតម្លៃនៃតួនាទីរបស់អាជីវកម្មក្នុងស្រុក។"

ការបង្កើតបណ្តាញធុរកិច្ច (SBN) នៅកម្ពុជា គឺជាព្រឹត្តិការណ៍ជាតិដ៏សំខាន់ ក្នុងការគាំទ្រដល់ចលនាបង្កើនអាហារូបត្ថម្ភសកល ដែលមានគោលដៅលុបបំបាត់បញ្ហាអាហារូបត្ថម្ភទូទាំងពិភពលោកត្រឹមឆ្នាំ២០៣០។ ចលនានេះទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់វិស័យឯកជនក្នុងការកែលម្អអាហារូបត្ថម្ភ និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

លោកស្រី ក្លែរ កូណាន់ តំណាងរបស់កម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជាបានមានប្រសាសន៍ថា "យើងខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានបង្កើតនូវបណ្តាញធុរកិច្ចនេះ និងទន្ទឹងការសហការជាមួយសមាជិកស្ថាបនិកទាំងចាស់ទាំងថ្មីនាពេលអនាគត។"

"ពួកយើងជឿជាក់ថា ការកែលម្អសមាសធាតុអាហារូបត្ថម្ភផលិតផលអាហារគឺជាជម្រើសឈ្នះឈ្នះ សម្រាប់អតិថិជនផង និងសម្រាប់អាជីវកម្មផង ពីព្រោះអាជីវកម្មណាដែលផ្តល់នូវអាហារូបត្ថម្ភល្អ នឹងនាំឱ្យអាជីវកម្មនោះមានលក្ខណៈពិសេសប្លែកពីអាជីវកម្មដទៃ ដូច្នេះនាំឱ្យមានកំណើននៃការលក់និងប្រាក់ចំណេញ។"

លោក លាង ឡេង ម្ចាស់ផលិតកម្មត្រីនិងទឹកស៊ីអ៊ីវ និងជាសមាជិកស្ថាបនិករបស់បណ្តាញធុរកិច្ចSBNកម្ពុជាបានមានមតិថា៖

"ខ្ញុំជឿជាក់ថា បណ្តាញធុរកិច្ចSBN នឹងបង្កើតនូវគំនិតនិងទំនាក់ទំនងថ្មីៗជាច្រើន ក៏ដូចជាអប់រំដល់សាធារណជនអំពីសារៈសំខាន់នៃអាហារូបត្ថម្ភ។ កត្តានេះនឹងបង្កើននូវតម្រូវការខ្ពស់ជាងមុន។

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ស.ជ.)

World Food Programme

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោកស្រី ជា ជូ

មន្ត្រីផ្នែកទំនាក់ទំនងនិងរបាយការណ៍

កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា

ទូរស័ព្ទលេខ៖ +855 78 565 283

អ៊ីម៉ែល៖ chou.chea@wfp.org